# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**តុលាការក្រុងភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌ

លេខ ១៣៧៥ ចុះថ្ងៃទី ២៧

ខែ សីហា ឆ្នាំ ២០០២

សាលក្រមព្រហ្មទណ្ឌ

លេខ ២៥ "ញ" ចុះថ្ងៃទី ២២

ខែ ឧសភា ឆ្នាំ ២០០៣

## តាមនាមប្រជារាស្ត្រខ្មែរ

## តុលាការក្រុងភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃ រដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។ បានបើកសវនាការជាសាធារណៈនៅតុលាការក្រុងភ្នំពេញ នាថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៣ ដោយមានសមាសភាពដូចតទៅ :

**ចៅក្រមជំនុំជំរះ**

លោក [redacted] ចៅក្រមតុលាការក្រុងភ្នំពេញ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការក្រុងភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីតុលាការក្រុងភ្នំពេញ

**មេធាវីការពារជនជាប់ចោទ**

លោកស្រី ពិន ចំនា

ដើម្បីជំនុំជំរះសំណុំរឿងព្រហ្មទណ្ឌលេខ ១៣៧៥ ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០២ ។ ដែលមានជនជាប់ចោទ :

១-ឈ្មោះ គ **ចសណរ** ភេទប្រុស អាយុ ២៣ឆ្នាំ សញ្ជាតិខ្មែរ កើតនៅព្រៃឈើទាល ឃុំព្រៃឈើទាល ស្រុកត្រាំកក់ ខេត្តតាកែវ សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃផ្ទះលេខ ៤៥ ផ្លូវលំ សង្កាត់ជ្រោយចង្វា ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ របររកស៊ី មិនពិតប្រាកដ នៅលីវ ឪពុកឈ្មោះ គ **សច** (រ) ម្តាយឈ្មោះ **ម សរ** (រ) ទោសពីមុន ធ្លាប់ជាប់គុកម្តង ឃុំខ្លួនថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០២ ។

ជាប់ចោទពីបទប្លន់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០២ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និង ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

**ដើមបណ្តឹងរដ្ឋប្បវេណី :**

១-ឈ្មោះ **ចា គត** ភេទប្រុស អាយុ ២៧ឆ្នាំ ជាតិខ្មែរ កើតនៅភូមិបឹងដែង ឃុំព្រែកកក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃនៅភូមិស្ពានខ្ពស់ ផ្លូវលេខ ៥ ក្រុមទី ៧ សង្កាត់គីឡូម៉ែត្រលេខ ៦ ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ របររកស៊ីជួសជុលទូរស័ព្ទ នៅលីវ ឪពុកឈ្មោះ **ឧ មចា** (រ) ម្តាយឈ្មោះ **ភ សទ** (រ ទោសពីមុន គ្មាន ។

សាលក្រមនេះចូលជាស្ថាពរនៅថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០៣ ដោយគ្មានភាគីណាមួយប្តឹងជំទាស់មក
ប្តឹងតវ៉ា និង ឧទ្ធរណ៍ក្នុងអំឡុងពេលកំណត់ច្បាប់ឡើយ ។
ភ្នំពេញ ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០៣
ក្រឡាបញ្ជី
[redacted]

២-ឈ្មោះ ឱ ទន ភេទប្រុស អាយុ ២៧ឆ្នាំ ជាតិខ្មែរ កើតនៅភូមិបឹងដែង ឃុំព្រៃកក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃ ផ្ទះលេខ ១៧០E1 ផ្លូវ ១៨២ សង្កាត់វាលវង់ ខណ្ឌ៧មករា ក្រុងភ្នំពេញ របររកស៊ីជាងជួសជុលរថយន្ត នៅលីវ ឪពុកឈ្មោះ **ឱ សខ** ( រ ) ម្តាយឈ្មោះ **ម សម** (ស) ទោសពីមុន *គ្មាន* ។

បានឃើញដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ ៤៨២ តព្រ ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៣ របស់ចៅក្រមស៊ើបអង្កេត ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ **គ មសណអ** បានឆ្លើយថា : នៅថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០២ វេលាម៉ោងប្រហែល ១០យប់ឈ្មោះ **ឆ** ដែលនៅផ្ទះជួលក្បែរផ្ទះសង្សាររបស់ខ្ញុំ បានពឹងខ្ញុំឱ្យជូនវាទៅបារទន្លេសាប ដើម្បីរកមើលសង្សាររបស់វា តែរកពុំឃើញទេ ក៏រៀបចេញមកវិញក៏បានឃើញម៉ូតូមួយម៉ាក C១០០ ពណ៌ព្រីងទុំ ពុំដឹងសេរីទេ មានជិះគ្នា ០៣នាក់ ប្រុស០២នាក់ ស្រីម្នាក់ ពេលនោះឈ្មោះ **ឆ** បានឱ្យខ្ញុំបើកទៅក្បែរម៉ូតូនោះដើម្បីមើលមុខស្រីនោះក្រែងលោជាសង្សាររបស់វា ខ្ញុំក៏បានបើកម៉ូតូទៅក្បែរម៉ូតូនោះ ស្រាប់តែម៉ូតូនោះមកប៉ះនឹងម៉ូតូខ្ញុំតែម្តង ក៏កើតជាការជជែកគ្នារហូតដល់មានការវាយតប់គ្នាឡើង ។ ពេលដែលវាយតប់គ្នានោះ គឺរូបខ្ញុំពុំបានវាយតប់ជាមួយគេទេ គឺឈ្មោះ **ឆ** ទេ ដែលជាអ្នកវាយជាមួយគេ ។ ហើយនៅពេលកើតហេតុនោះខ្ញុំគ្រាន់តែដឹងថា ប៉ូលីសបានបាញ់អាវុធមួយគ្រាប់ ហើយពេលកើតហេតុខ្ញុំនឹងឈ្មោះ **ឆ** គឺពិតជាពុំបានប្លន់ម៉ូតូរបស់គេទេ គឺគ្រាន់តែវាយតប់គ្នាដោយរឿងប៉ះម៉ូតូគ្នាប៉ុណ្ណោះ ។ ចំពោះឈ្មោះ **ឆ** នេះ គឺខ្ញុំទើបតែស្គាល់ប្រហែលមួយខែទេ ដោយសារវាជួលផ្ទះនៅក្បែរសង្សារខ្ញុំ ចំណែកទីលំនៅរបស់វា និង សាវតាររបស់វាខ្ញុំពុំស្គាល់ទេ ។ ខ្ញុំសូមសំណូមពរដល់តុលាការមេត្តាជួយរកយុត្តិធម៌ឱ្យខ្ញុំផង ព្រោះខ្ញុំពុំបានប្រព្រឹត្តដូចពាក្យគេចោទឡើយ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **ម គត** ( អវត្តមាន ) តាមកំណត់ហេតុយកចម្លើយរបស់ឈ្មោះ **ម គត** ចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០២ បានឆ្លើយថា : កាលពីថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០២ វេលាម៉ោងប្រហែល ១១យប់ ខ្ញុំបានជិះម៉ូតូមួយគ្រឿងម៉ាក C១០០ សេរី ២០០០ ជិះគ្នា ០៣នាក់ គឺមិត្តភក្តិរបស់ខ្ញុំម្នាក់ រូបខ្ញុំ និង ស្រីម្នាក់ជាស្រីឡង់សេ ។ ពីដំបូងខ្ញុំ និង មិត្តភក្តិបានចូលទៅរាំលេងក្នុងបារគង្គា តែដោយឃើញមនុស្សច្រើនពេក ពួកខ្ញុំក៏ចេញមកវិញ មានបំណងមករាំលេងនៅបារមេគង្គ ស្រាប់តែធ្វើដំណើរមកដល់ចំណុចក្រោយឆ្នេរទន្លេមានម៉ូតូមួយគ្រឿងជិះគ្នា ០២នាក់វ៉ាម៉ូតូពួកខ្ញុំ ហើយបានចាក់ម៉ូតូខ្ញុំផ្តួល ហើយពេលនោះម៉ូតូក៏បានឈប់ទាំង ០២គ្រឿង មានម្នាក់ជិះពីខាងក្រោយម៉ូតូ ពួកវាបានដកអាវុធខ្លីមួយដើមពុំស្គាល់ម៉ាក បានភ្ជង់ពួកខ្ញុំឱ្យចុះចេញពីលើម៉ូតូ ហើយពេលនោះដែលពួកវាក៏បានបាញ់មួយគ្រាប់តម្រង់មិត្តភក្តិខ្ញុំ តែសំណាងល្អកាំភ្លើងនោះពុំបានផ្ទុះទេ ដោយឃើញកាំភ្លើងបាញ់អត់ផ្ទុះដូច្នេះហើយមិត្តភក្តិខ្ញុំក៏ស្ទុះទៅប្រតាយប្រតប់តែម្តង ហើយខ្ញុំក៏បានស្រែកថា ចោរៗ ប៉ូលីសដែលយាមនៅអង្គភាពអន្តរាគមន៍បានបាញ់ចំនួន ០៣គ្រាប់ ហើយនៅពេលនោះដែរ អាចោរម្នាក់ជាអ្នកកាន់កាំភ្លើងក៏រត់គេចខ្លួនបាត់ទៅនៅសល់តែម្នាក់ដែលចាប់បាននៅពេលកើតហេតុនេះ ។ ចំពោះម៉ូតូរបស់ខ្ញុំ ដែលចោរប្លន់នេះ គឺប៉ូលីសបានប្រគល់ឱ្យខ្ញុំវិញហើយ ។ ខ្ញុំពុំទាមទារអ្វីទេក្នុងរឿងនេះ គឺសូមឱ្យតុលាការផ្តន្ទាទោសទៅតាមផ្លូវច្បាប់ចុះ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **ឱ ទន** ( អវត្តមាន ) តាមកំណត់ហេតុយកចម្លើយរបស់ឈ្មោះ **ឱ ទន** ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០២ បានឆ្លើយថា : នៅថ្ងៃកើតហេតុពីដំបូង វេលាម៉ោងប្រហែល ០៩យប់ ខ្ញុំ និង មិត្តភក្តិរបស់ខ្ញុំម្នាក់ទៀតឈ្មោះ **ម គត** បាននាំគ្នាទៅផឹកស៊ីនៅហាង ឆាយ ហេង លុះប្រហែលម៉ោងជាង ១០យប់

ទើបនាំគ្នាចេញពីហាង ឆាយ ហេង ដោយយកនារីម្នាក់ជាអ្នកលក់ប៊ីយែរទៅជាមួយផង បានដើរលេងនៅតាមសួនច្បារវិមានឯករាជ្យមួយសន្ទុះ ទើបនាំគ្នាទៅរាំលេងនៅបារប៉ាស៊ីហ្វិក តែពេលចូលទៅនោះពុំមានកន្លែងអង្គុយ ក៏ត្រឡប់ចេញមកវិញទៅបារឆ្នេរទន្លេ ចូលទៅក៏អត់មានកន្លែងអង្គុយទៀត ក៏ចេញមកវិញទៀត នាំគ្នាជិះម៉ូតូឆ្ពោះទៅបារគង្គា ចូលទៅបារលើកទី ០៣នេះក៏អត់មានកន្លែងអង្គុយដែរ ក៏នាំគ្នាត្រឡប់មកវិញ ដើម្បីទៅបារមេគង្គតែម្តង គឺជិះម៉ូតូឌុបគ្នា ០៣នាក់ ជិះតាមផ្លូវខាងក្រោយបារឆ្នេរទន្លេមុខអង្គភាពប៉ូលីសអន្តរាគមន៍ ស្រាប់តែមកដល់ខាងក្រោយបារឆ្នេរទន្លេមានម៉ូតូមួយគ្រឿងម៉ាក C១០០ សេរី ២០០២ ជិះគ្នា ០២នាក់ បានជិះអែបម៉ូតូរបស់ខ្ញុំ ហើយចាក់ម៉ូតូរបស់ខ្ញុំ ដែលខ្ញុំកំពុងតែបើកបរបណ្តោលឱ្យដួល ហើយម៉ូតូរបស់ចោរក៏ឈប់ដែរ ។ ក្រោយពេលម៉ូតូរបស់វាឈប់ហើយមានគ្នាវាម្នាក់ ដែលជិះខាងក្រោយបានដកអាវុធពីចង្កេះមកភ្ជង់ខ្ញុំ តែអាវុធនោះពុំស្គាល់ម៉ាកទេ ពួកវាបានឱ្យខ្ញុំចុះចេញពីលើម៉ូតូ តែពេលនោះខ្ញុំពុំព្រមចេញ ស្រាប់តែម្នាក់កាន់កាំភ្លើងបាញ់មកលើខ្ញុំ តែសំណាងល្អកាំភ្លើងនោះមិនផ្ទុះ ហើយវាក៏បានស្ទុះមកទាញដៃម៉ូតូរបស់ខ្ញុំ ខ្ញុំក៏បានយកទូរស័ព្ទរបស់ខ្ញុំម៉ាកស៊ីម៉ែន C១១ គប់ចំក្បាលអ្នកកាន់កាំភ្លើងនោះ ។ ពេលនោះដែរឈ្មោះ **ត** ក៏បានស្រែកថា ចោរៗប៉ូលីសដែលនៅយាមអង្គភាពអន្តរាគមន៍បានបាញ់កាំភ្លើងចំនួន ០៣គ្រាប់ ដោយមានការបាញ់កាំភ្លើងពីប៉ូលីសដូច្នេះហើយ ទើបចោរម្នាក់ដែលជាអ្នកកាន់កាំភ្លើងរត់គេចខ្លួនបាត់តែម្តង គឺប៉ូលីសឃាត់ខ្លួនបានតែម្នាក់ដែលសមត្ថកិច្ចបានបញ្ជូនមកតុលាការនេះ ។ ខ្ញុំសូមសំណូមពរឱ្យតុលាការផ្តន្ទាទោសក្រុមចោរប្លន់នេះតាមច្បាប់ ចំណែកម៉ូតូ សមត្ថកិច្ចបានប្រគល់មកឱ្យឈ្មោះ **ត** វិញហើយ ខ្ញុំអត់ទាមទារអ្វីទេ ។

-សាក្សីបំភ្លឺឈ្មោះ **សចរ** ( អវត្តមាន ) តាមកំណត់ហេតុយកចម្លើយ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០២ បានឆ្លើយថា នាងខ្ញុំមានមុខរបរលក់ប៊ីយែរនៅហាង ឆាយ ហេង នៅថ្ងៃកើតហេតុនោះឈ្មោះ **ឃ គត** ម្ចាស់ម៉ូតូជាជនរងគ្រោះ បានចូលហូបប៊ីយែររបស់ខ្ញុំនៅហាង ឆាយ ហេង រហូតដល់ម៉ោង ១០យប់ ទើបចេញ ហើយខ្ញុំក៏បានចេញទៅដើរលេងជាមួយគាត់ គឺដើរលេងតាមសួនវិមានឯករាជ្យ ក្រោយមកក៏ចេញទៅបារប៉ាស៊ីហ្វិក តែដល់មនុស្សច្រើនពេកអត់កន្លែងអង្គុយ ក៏ចេញមកវិញទៅបារទន្លេសាប ក៏អត់កន្លែងអង្គុយ ក៏ចេញមកវិញទៀត ហើយក៏ចេញទៅបារគង្គាជាលើកទី ៣ទៀតក៏អត់កន្លែងអង្គុយទៀត ក៏ចេញមកវិញនាំគ្នាទៅបារមេគង្គវិញ គឺជិះតាមផ្លូវក្រោយឆ្នេរទន្លេមកដល់ខាងក្រោយភោជនីយដ្ឋានឆ្នេរទន្លេ ស្រាប់តែមានម៉ូតូមួយគ្រឿងម៉ាក C១០០ សេរី ២០០២ ជិះគ្នា ០២នាក់ បានមកចាក់ម៉ូតូរបស់ខ្ញុំកំពុងជិះបណ្តោលឱ្យដួល ហើយអាម្នាក់ជិះខាងក្រោយបានដកកាំភ្លើងភ្ជង់មកលើពួកខ្ញុំ ខ្ញុំឃើញដូច្នេះក៏លោតចុះពីលើម៉ូតូរត់តែម្តង ហើយស្រែកថា ចោរៗ ដោយភ័យខ្លាំងពេក ខ្ញុំក៏ជិះម៉ូតូឌុបមកផ្ទះវិញ ។

-លោកតំណាងអយ្យការបានសន្និដ្ឋានថា : កាលពីថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០២ ពិតជាមានអំពើប្លន់ ប៉ុន្តែការឆ្លើយរបស់ជនជាប់ចោទឈ្មោះ គ **មសណរ** ថា ខ្លួនពិតជាបានជូនឈ្មោះ ឆ ដើររកសង្សារក៏បានជិះម៉ូតូមកប៉ះម៉ូតូមួយទៀត គប្បីភាគីទាំងពីរមិនត្រូវគេចខ្លួន គឺដោះស្រាយនៅមុខសមត្ថកិច្ច ប៉ុន្តែការស៊ើបមានតែចម្លើយបដិសេធពុំមានភស្តុតាងដោះបន្ទុកទេ ។ ហើយជនជាប់ចោទមានស្មារតីល្អអាចទទួលខុសត្រូវចំពោះមុខច្បាប់ ។ ដូច្នេះតំណាងអយ្យការសូមតម្កល់ការចោទប្រកាន់ដដែល ។

-មេធាវីបានសន្និដ្ឋានថា : ចំពោះកូនក្តីខ្ញុំឈ្មោះ គ **មសណរ** មិនបានប្រព្រឹត្តអំពើប្លន់ទេ គឺវាគ្មានធាតុផ្សំបទល្មើសប្លន់ទាល់តែសោះ ប៉ុន្តែរឿងនេះឃើញថា ពេលម៉ូតូទាំង ០២ ដួលជាមួយគ្នាឈ្មោះ ឆ ដែលរត់គេចខ្លួនបាត់បានវាយតប់គ្នាទៅវិញទៅមកជាមួយជន ដែលអះអាងថា ជាជនរងគ្រោះទាំង ០២ ។ ក្នុងពេលប្រទុះសារវាយគ្នានេះ ប៉ូលីសដែលមានទីតាំងនៅជិតនោះបានលើកកាំភ្លើងបាញ់ឡើងលើ នោះសរបញ្ជាក់ថា បើកូនក្តីខ្ញុំជាអ្នកប្លន់ ប្រាកដជារត់គេចខ្លួនបាត់ទៅហើយ ដូច្នេះខ្ញុំសូមឱ្យតុលាការមេត្តាពិនិត្យពិចារណាឱ្យបានច្បាស់លាស់ និង សុំឱ្យរួចផុតពីការចោទប្រកាន់ចំពោះកូនក្តីខ្ញុំនេះ ។

-ជនជាប់ចោទបាននិយាយសំដីចុងក្រោយថា សូមតុលាការ មេត្តារកយុត្តិធម៌ឱ្យខ្លួនផង និង សុំឱ្យរួចផុតពីការចោទប្រកាន់ ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ក្រឡាបញ្ជីអានចម្លើយជនរងគ្រោះ និង សាក្សី

-ក្រោយពីបានពិនិត្យឯកសារភស្តុតាង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

**<u>តុលាការក្រុងភ្នំពេញ</u>**

-ក្រោយពីបានពិនិត្យពិចារណា ត្រឹមត្រូវតាមច្បាប់ហើយ យល់ឃើញថា :

-រឿងនេះ គឺជាទំនាស់គ្នា ក្រោយពីការតាមរកសង្សាររបស់ឈ្មោះ **រតន** ហៅ **ឆ** ដែលពេលនោះ គឺមានការប៉ះម៉ូតូគ្នាដួល ហើយមានការវាយតប់គ្នាទៅវិញទៅមក ។

-ប្រសិនណាបើឈ្មោះ **គ មសណអ** ជាអ្នកប្រព្រឹត្តបទល្មើសរួមជាមួយឈ្មោះ **រតន** ហៅ **ឆ** នោះឈ្មោះនេះមិនមែនរាយការណ៍ឱ្យសមត្ថកិច្ចនៅពេលដែលប៉ូលីសមកដល់ ។

-ក្នុងស្ថានភាពសង្គមសព្វថ្ងៃ ប្រសិនណាបើគូរទំនាស់ម្ខាងមានចេតនាអាក្រក់ គ្រាន់តែស្រែកថា ភាគីទំនាស់ខ្លួនជាចោរលួច ឬ ជាចោរប្លន់ ប្រជារាស្ត្រប្រាកដជាចោមរោមវាយសម្លាប់មិនខាន ដែលរឿងនេះធ្លាប់មានជារឿយៗនៅក្នុងសង្គមយើង ។

-ក្នុងពេលសវនាការនេះ ជនរងគ្រោះ និង សាក្សីមិនបានចូលមកបំភ្លឺតុលាការតាមការកោះហៅទេ ដែលនេះអាចសរបញ្ជាក់ថា អ្នកទាំងនេះមិនមានការទទួលខុសត្រូវនូវអំពើរបស់ខ្លួន ដែលបានចោទប្រកាន់ឈ្មោះ **គ មសណអ** ឱ្យសមត្ថកិច្ចចាប់ឡើយ ។

-ការលើកឡើងរបស់លោកតំណាងអយ្យការក្នុងពេលសវនាការនេះ គប្បីតុលាការពិនិត្យពិចារណា សំរេចតាមច្បាប់ ។

-សេចក្តីសន្និដ្ឋានរបស់មេធាវី ដែលបានលើកឡើងក្នុងពេលសវនាការនេះ ដែលបានបញ្ជាក់ច្បាស់ថា វាគ្មានធាតុផ្សំបទល្មើសប្លន់ទាល់តែសោះ ប៉ុន្តែរឿងនេះឃើញថា ពេលម៉ូតូទាំង០២ដួលជាមួយគ្នាឈ្មោះ **រតន** ហៅ **ឆ** ដែលរត់គេចខ្លួនបាត់បានវាយគ្នាទៅវិញទៅមកជាមួយជនដែលអះអាងថា ជាជនរងគ្រោះទាំង ០២ ។ ក្នុងពេលប្រទុះសារ៉ាយគ្នានេះ ប៉ូលីសដែលមានទីតាំងជិតនឹងបានលើកកាំភ្លើងបាញ់ឡើងលើ ដែលនេះរឹតតែបញ្ជាក់ច្បាស់ថា ប្រសិនបើឈ្មោះ **គ មសណអ** ជាជនល្មើសវាប្រាកដជាគេចខ្លួនបាត់ហើយ វាមិនមែនរៀបរាប់ប្រាប់ប៉ូលីសនូវសាច់រឿងនេះទេ ខ្ញុំសូមឱ្យតុលាការមេត្តាពិចារណាឱ្យបានច្បាស់លាស់ និង ឱ្យរួចផុតពីការចោទប្រកាន់ចំពោះកូនក្តីខ្ញុំនេះ ។

-គ្មានពិរុទ្ធភាពគ្រប់គ្រាន់ក្នុងការចោទប្រកាន់លើឈ្មោះ **គ មសណអ** ភេទប្រុស អាយុ ២៣ឆ្នាំ ជនជាតិខ្មែរ ពីបទប្លន់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០២ ឡើយ គប្បីតុលាការសំរេចឱ្យរួចផុតពីការចោទប្រកាន់ជាស្ថាពរ ។

-សំដីចុងក្រោយរបស់ជនជាប់ចោទ ដែលបានសុំឱ្យតុលាការលើកលែងចោទប្រកាន់នោះ គប្បីតុលាការពិនិត្យសំរេចទៅតាមច្បាប់ ។

## ហេតុដូច្នេះសំរេច

១-ឱ្យរួចផុតពីបទចោទប្រកាន់លើឈ្មោះ គ **មសណអ** ភេទប្រុស អាយុ ២៣ឆ្នាំ ជាតិខ្មែរ ពីបទប្លន់ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០២ ហើយត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៦ នៃច្បាប់ ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋជាស្ថាពរ ។

២-បង្គាប់មកប្រធានមន្ទីរពន្ធនាគារម១ នៃក្រសួងមហាផ្ទៃឱ្យដោះលែងឈ្មោះ គ **មសណអ** ជាបន្ទាន់ បើសិនជននេះមិនត្រូវឃុំខ្លួនក្នុងបទល្មើសអ្វីផ្សេងទៀតទេ ។

៣-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ កំបាំងមុខជនរងគ្រោះ សំរេចបើកផ្លូវឧទ្ធរណ៍ក្នុងកំណត់ច្បាប់ គិតចាប់ពីថ្ងៃផុតបណ្តឹងទាស់ ។

**ចៅក្រមជំនុំជំរះ**

**ហត្ថលេខា និង ត្រា**

[redacted]

---

**បានចតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

*ភ្នំពេញ, ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០៣*

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ចៅក្រម**

[redacted]